ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អង្គភាពគ្រប់គ្រងគម្រោង
លេខ:០១០/០៨ របក.អគគ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មេសា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មេសា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០០៨ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២០០៦-២០១០ ជូនក្រសួងផែនការ

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំអនុម័តសេចក្តីព្រាងការវិភាគលើលក្ខណ:វិនិច្ឆ័យ ស្តង់ដា និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៨ នៅសណ្ឋាគារអាំង-ទែរកុងទីណង់តាល់ (Inter-Continental Hotel)

### ខ. ការងារកំណែទម្រង់

-រៀបចំសិក្ខាសាលាស្តីពី កម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិលនៅតាមបណ្តាខេត្ត-ក្រុងទាំងឡាយ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរ សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសាលាខេត្តកំពង់ធំ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨, នៅសាលាខេត្តសៀមរាប នៅថ្ងៃ ទី២២ ខែមេសា ឆ្នាំ២០០៨ និងនៅសាលាខេត្តបាត់ដំបង នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨។

-រៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ (TWG/LJR) នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ នាទី នៅទីស្តីការគណ:រដ្ឋមន្ត្រី (អតីតរដ្ឋសភាជាតិ)។

-រៀបចំប្រជុំក្រុមការងារជាន់ខ្ពស់ សម្រាប់គម្រោងតុលាការគំរូដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាង ការវិភាគលើលក្ខណ:វិនិច្ឆ័យ ស្តង់ដា និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា

នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៨ ចាប់ពីម៉ោង ៨ៈ៣០នាទី ដល់ម៉ោង ១២ៈ៣០នាទី នៅសណ្ឋាគារអាំង ទែរកុងទីណង់តាល់ (Inter-Continental Hotel )។

-ពិនិត្យរៀបចំ TORs គម្រោងឧបត្ថម្ភបន្តដល់ការរៀបចំប្រព័ន្ធទិន្នន័យការបណ្តុះបណ្តាលសិទ្ធិមនុស្ស

-បន្តការប្រជុំរៀបចំប្រព័ន្ធសូចនាករផ្ទៃក្នុងអង្គភាពគ្រប់គ្រងគម្រោង

-ជួបពិភាក្សាជាមួយក្រុមជំនាញ IMS ពី Denmark អំពីការងាររៀបចំប្រព័ន្ធសូចនាករ

-ប្រជុំជាមួយតំណាងអ្នកផ្តល់ជំនួយសំខាន់ៗ

ពិភាក្សាអំពីគោលការណ៍នៃការរៀបចំសូចនាករតាមដាន កំណែទម្រង់ច្បាប់ និងតុលាការនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨

## គ. ផ្សេងៗ

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពីការសិក្សាលទ្ធភាព បង្កើតសាលា ជំម្រះក្តីថ្នាក់មូលដ្ឋាន ការលែងលះ និងប្រព័ន្ធច្បាប់ប្រពៃណី រៀបចំដោយ UNDP នៅសណ្ឋាគារ Himawari នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨

-ចូលរួមស្តាប់បទបង្ហាញពី លទ្ធផលនៃការស្រាវជ្រាវអំពីគំនិតផ្តួចផ្តើម ការយល់ដឹងអំពីជំនួយផ្នែកច្បាប់ នៅសណ្ឋាគារសាន់វ៉េ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៨។

## ២-សន្និដ្ឋាន

ក្នុងខែ មេសា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាព ប្រតិបត្តិបានបន្តការងាររៀបចំសិក្ខាសាលា ផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិល លើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តសៀមរាប និងខេត្តបាត់ដំបង និងបានរៀបចំប្រជុំអនុម័តសេចក្តីព្រាងការវិភាគលើលក្ខណៈវិនិច្ឆ័យ ស្តង់ដា និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា នៅថ្ងៃ ទី ២៩ ខែមេសា ឆ្នាំ២០០៨ នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ (Inter-Continental Hotel )និងបន្តការងាររៀបចំប្រព័ន្ធសូចនាករសម្រាប់តាមដានកាកែទម្រង់ច្បាប់ និងតុលាការ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-រៀបចំសិក្ខាសាលាស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅក្រុងព្រះសីហនុ

-សហការជាមួយអគ្គស្នងការរងនៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដើម្បីរៀបចំសន្និសីទជាតិស្តីពីការ រីកចម្រើនរបស់ប្រជាពលរដ្ឋ នៅចុងខែឧសភា ឆ្នាំ២០០៨។

រាជធានី ភ្នំពេញ ថ្ងៃទី ខែឧសភា ឆ្នាំ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊្វូង សុកុល

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង